# ឯកសារទស្សនាទាន
# វេទិការសិក្សារៀនសូត្រការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២១

# ស្តីពី
# ពន្ធដារនិងច្បាប់នៃប្រទេសកម្ពុជា

ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៨ វេលាម៉ោង៨: 00នាទី ព្រឹកដល់ម៉ោង៥:០០នាទីរសៀល
នៅជាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

## I.សេចក្តីផ្តើម

អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាហៅកាត់ថា (គ.ស.ក) គឺជាអង្គការសមាជិកភាពដែលបានបង្កើតឡើងដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩០ ដោយបានដើរតួនាទីចំបងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ វិជ្ជាជីវៈ គណនេយ្យភាព តម្លាភាព អភិបាលកិច្ច និងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាពចំពោះអង្គការសង្គមស៊ីវិលដែលកំពុងប្រតិបត្តិការវិស័យផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។

នៅក្នុងដំណាក់កាលទី៣នៃផែនការកម្មវិធីរបស់អង្គការ គ.ស.ក សម្រាប់រយៈពេលប្រាំឆ្នាំ២០១៧ដល់២០២១។ គោលដៅអង្គការគ.ស.កគឺជាអង្គការសង្គមស៊ីវិលមួយដែលមានកិច្ចសហការដ៏រឹងមាំនិងមានសមត្ថភាពឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍនៅកម្ពុជា។ គោលដៅផែនការកម្មវិធីគឺ: ១) បង្កើនប្រសិទ្ធភាពនិងផលប៉ះពាល់នៃអង្គការសង្គមស៊ីវិល និង ២)ធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល។ ដើម្បីឆ្លើយតបទៅនឹងគោលដៅរបស់ខ្លួន អង្គការ គ.ស.ក បានរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពនិងឪកាសសិក្សារៀនសូត្រសម្រាប់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ដើម្បីមានឥទ្ធិពលដល់ការគិត និងការអនុវត្តន៍របស់ពួកគេ និងដើម្បីផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់សមស្របក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃអង្គការសង្គមស៊ីវិលទាំងនោះ។

យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំងប្រាំពីរគឺ ការសិក្សារៀនសូត្រនិងអភិវឌ្ឍន៍សមត្ថភាពសម្រាប់សមាជិករបស់អង្គការគសក និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតដែលបានចាប់អារម្មណ៍។ ក្នុងចំណោមកម្មវិធីនេះគឺ វេទិកាសិក្សារៀនសូត្រអំពី ការគ្រប់គ្រងធនធានមនុស្ស ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព័ត៌មានទំនាក់ទំនងបច្ចេកវិទ្យា និង ការគ្រប់គ្រងហិរញ្ញវត្ថុ ។ វេទិកាសិក្សារៀនសូត្រនេះមានសារៈសំខាន់ណាស់ក្នុងការកសាងសមត្ថភាពសមាជិករបស់ខ្លួនដើម្បីឲ្យការអនុវត្តន៍ផ្តល់សេវាកម្មរបស់ពួកគេកាន់តែ


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

ប្រសើរឡើង។

ដើម្បីធានាបាននូវគុណភាពនៃវេទិកាសិក្សារៀនសូត្រនេះ អង្គការគសកបានបង្កើតក្រុមការងារដើម្បីជួយផ្តល់ការពិភាក្សានិងយោបល់សម្រាប់ការសិក្សារៀនសូត្ររបស់អង្គការសហគមន៍នៅក្នុងប្រទេសកម្ពុជា។ ក្រុមការងារនេះបានដើរតួនាទីគណៈកម្មការទទួលខុសត្រូវរួមដើម្បីផ្តល់ជាយុទ្ធសាស្ត្រ និងបច្ចេកទេសគាំទ្រដល់អង្គការសហគមន៍ក្នុងការលើកកំពស់និងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានមនុស្ស ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព័ត៌មានទំនាក់ទំនងបច្ចេកវិទ្យា និង ការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងអង្គការរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងវិស័យអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។

ដើម្បីបន្តការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់អង្គការសហគមន៍និងពង្រឹងសមត្ថភាពបន្ថែមអំពីអភិបាលកិច្ចល្អនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា អង្គការគសកនឹងត្រូវបានអនុវត្តបន្តវេទិកាសិក្សារៀនសូត្រលើកទី២១នៃការគ្រប់គ្រងហិរញ្ញវត្ថុដោយផ្អែកលើប្រធានបទដែលបានជ្រើសរើសដោយក្រុមការងារនិងលើកឡើងដោយអង្គការសិក្ខាកាមដែលបានចូលរួមក្នុងវេទិកាសិក្សារៀនសូត្រកាលពីឆ្នាំកន្លងទៅគឺ **ពន្ធដារនិងច្បាប់នៃប្រកម្ពុជា។**

វេទិកាសិក្សារៀនសូត្រលើកទី២១នៃការគ្រប់គ្រងហិរញ្ញវត្ថុគឺត្រូវបានកំណត់អ្នកចូលរួមជំនាញផ្នែកហិរញ្ញវត្ថុដែលអញ្ជើញមកពីអង្គការសមាជិក និងមិនមែនសមាជិករបស់អង្គការគសក។ វេទិកានេះនិងប្រារព្ធឡើងពេញមួយថ្ងៃនៅថ្ងៃទី២៧ខែមិនាឆ្នាំ២០១៨ នៅអាគារដាយកូនៀសិនធើ ដែលមានគោលបំណងជាក់លាក់ លទ្ធផលរំពឹងទុករយៈពេលមធ្យម និងកម្មវិធីលំអិតដូចខាងក្រោមនេះ៖

## II. កាលបរិច្ឆេទនិងទីកន្លែងនៃវេទិកាសិក្សារៀនសូត្រ

វេទិកានេះនឹងប្រារព្ធធ្វើឡើងពេញមួយថ្ងៃនៅថ្ងៃទី**២៧ខែមិនាឆ្នាំ២០១៨ វេលាម៉ោង៨: 00នាទី ព្រឹកដល់ម៉ោង៥:00នាទី**សៀលនៅដាយកូនៀសិនធើ ផ្ទះលេខ១៩-២១ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

## III. គោលបំណងនៃវេទិកាសិក្សារៀនសូត្រ

- ដើម្បីរំលឹកមេរៀនពីមុនឡើងវិញក្នុងការជួយឲ្យសិក្ខាកាមពង្រឹងជំនាញ អំពីរបៀបធ្វើការត្រួតពិនិត្យផ្ទៃក្នុងឲ្យកាន់តែរឹងមាំនិងការគ្រប់គ្រងហានិភ័យនិងវិភាគហិរញ្ញវត្ថុ
- ដើម្បីជួយសិក្ខាកាមយល់ច្បាស់អំពីរបៀបនៃការអនុវត្តន៍តាមច្បាប់ពន្ធដារនៃប្រទេសកម្ពុជា
- ដើម្បីបង្កើតបរិយាកាសវេទិការៀនសូត្រនិងចែករំលែកក៏ដូចជាកសាងបណ្តាញឲ្យកាន់តែ មានភាពរឹងមាំក្នុងចំណោមអង្គការសង្គមស៊ីវិលនិងការទំនាក់ទំនងជាមួយមន្ត្រីពន្ធដារឲ្យកាន់តែមានប្រសិទ្ធភាព



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## IV. លទ្ធផលរំពឹងទុករយៈពេលមធ្យម

- សិក្ខាកាមនឹងកាន់តែយល់ដឹងអំពីរបៀបធ្វើការត្រួតពិនិត្យផ្ទៃក្នុងឲ្យកាន់តែរឹងមាំ
- សិក្ខាកាមនឹងកាន់តែយល់ច្បាស់ទៅលើរូបភាពរួមនៃប្រពន្ធ័ពន្ធដារនិងការអនុវត្តន៍
- សិក្ខាកាមនឹងកាន់តែយល់ច្បាស់ពីភាពខុសគ្នានៃប្រភេទពន្ធ ការរៀបចំបង់ពន្ធ និងការប្រកាសពន្ធ
- សិក្ខាកាមនឹងមានឱកាសច្រើនក្នុងការរៀនសូត្រ ការចែករំលែក និងការទំនាក់ទំនងគ្នាក្នុងចំណោមសិក្ខាកាមដែលមានជំនាញស្រដៀងគ្នានិងការទំនាក់ទំនងជាមួយមន្ត្រីពន្ធដារឲ្យកាន់តែមានប្រសិទ្ធភាព។

## V. សិក្ខាកាមគោលដៅ

វេទិកាសិក្សារៀនសូត្រនេះនឹងផ្តល់ជូនសិក្ខាកាមអបប្បរមា៨០ទៅ១០០នាក់ដែលអញ្ជើញមកពីសមាជិកនិងមិនមែនជាសមាជិករបស់អង្គការគសកដែលមានវិជ្ជាជីវៈផ្នែកហិរញ្ញវត្ថុ។ សិក្ខាកាមម្នាក់ៗគួរត្រូវបានកំណត់កម្រិតបុគ្គលិកថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងថ្នាក់គ្រប់គ្រងកណ្តាលរបស់អង្គការ ហើយពួកគេនឹងមានការប្តេជ្ញាចិត្តយកទៅអនុវត្តនូវអ្វីដែលបានរៀននៅក្នុងអង្គការរបស់ពួកគេ។

សូមស្វាគមន៍សិក្ខាកាមដែលអញ្ជើញមកពីអង្គការមិនមែនសមាជិករបស់អង្គការគសក ប៉ុន្តែតម្រូវឲ្យចូលរួមបង់វិភាគទានទៅតាមគោលការណ៍ដែលបានចែងនៅក្នុងគោលនយោបាយសេវាកម្មអភិវឌ្ឍសមត្ថភាព ដើម្បីយកទៅជួយគាំទ្រផ្នែករៀបចំភស្តុភា។

## VI. កម្មវិធីលំអិត

| ពេលវេលា | មាតិកាសំខាន់ៗ | វាគ្មិនដោយ |
|---|---|---|
| 07:30-08:00 | ចុះបញ្ជីវត្តមាន | • **អ្នកស្រី ស្រេង សោភ័ណលក្ខិណា**<br>ជំនួយការផ្នែកកម្មវិធី<br>អង្គការគសក |
| 08:00-08:20 | គោរពទង់ជាតិ | • **អង្គសិក្ខាកាម** |
| | កិច្ចស្វាគមន៍<br>ការណែនាំអំពីគោលបំណងនៃវេទិកាសិក្សារៀនសូត្រ<br>និងការប្រកាសជូនដំណឹងទូទៅ | • **អ្នកស្រី កែវ ម៉ារ៉ា**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ<br>អង្គការគសក |
| 08:20-08:30 | កិច្ចស្វាគមន៍ និង សន្ទរកថាបើកកម្មវិធី | • **លោក ឃន ប៊ុនថុង**<br>ប្រធានផ្នែកប្រតិបត្តិការ<br>អង្គការគសក |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

| | | |
|---|---|---|
| 08:30-09:45 | <u>**វគ្គទី២:**</u> រំលឹកមេរៀនឡើងវិញស្តីពី "ការត្រួត ពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងហានិភ័យ និង វិភាគហិរញ្ញវត្ថុ" | • **លោកស្រី កែន សុភាព**<br>ប្រធានគ្រប់គ្រងហិរញ្ញវត្ថុនិងរដ្ឋបាល<br>Heinrich Böll Stiftung |
| 9:45:- 10:00 | **សម្រាកពិសារអាហារសម្រន់** | All |
| 10:00-10:10 | **មតិស្វាគមន៍** | • **លោក ទី សុខុន**<br>ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម<br>**និង មន្ត្រីពន្ធដារផ្សេងទៀត**<br>1. **លោក សុខ ផៀង**<br>អនុប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ<br>2. **លោក ម៉ា បូរ៉ា**<br>អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម<br>3. **លោក អាន សំណាង**<br>ប្រធានការិយាល័យនីតិកម្ម<br>4. **លោកស្រី សាវិន វីនីហ្សា**<br>អនុប្រធានការិយាល័យនីតិកម្ម<br>5. **លោកស្រី កើត សារ៉ាយ**<br>មន្ត្រីការិយាល័យនីតិកម្ម |
| 10:10-12:00 | <u>**វគ្គទី៣:**</u> **សេចក្តីណែនាំនៃច្បាប់ពន្ធដារប្រទេសកម្ពុជា មានដូចជា:**<br>- ច្បាប់និងបទប្បញ្ញត្ត<br>- ប្រព័ន្ធពន្ធដារនៃប្រទេសកម្ពុជា<br>- សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកបង់ពន្ធ<br>- ប្រភេទនៃពន្ធដារ<br>**សំណួរនិងចម្លើយ** | • **លោក សុខ ផៀង**<br>អនុប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ<br>• **អង្គសិក្ខាកាម** |
| | <u>**វគ្គទី៣ (ត):**</u> **ការរៀបចំពន្ធដារនិងការប្រកាសពន្ធ**<br>- ពន្ធលើប្រាក់បៀវត្ស<br>- ស្ថានភាពនិវេសដ្ឋាន | • **លោក ម៉ា បូរ៉ា**<br>អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម |

| | | |
|---|---|---|
| | - បង់ពន្ធលើប្រាក់ចំណេញនិងអតិប្បរមាពន្ធ<br>- អត្រាពន្ធប្រាក់បៀវត្សនិងការគិតពន្ធ<br>- ផលប្រយោជន៍ប្រាក់សន្សំនិងពន្ធ<br>- ទម្រង់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ<br>- ការប្រកាសពន្ធលើប្រាក់ចំណេញ<br>**សំណួរនិងចម្លើយ** | • **អង្គសិក្ខាកាម** |
| 12:00-01:30 | **សម្រាកពិសារអាហារសាមគ្គី** | • **អង្គសិក្ខាកាម** |
| 01:30-01:35 | **ល្បែងថាមពល** | • **អង្គសិក្ខាកាម** |
| 01:35-03:45 | **<u>វគ្គទី៤:</u> ពន្ធកាត់ទុក**<br>- ទស្សនៈនៃពន្ធកាត់ទុក<br>- អត្រាពន្ធកាត់ទុក<br>- ភ្នាក់ងារពន្ធកាត់ទុក<br>- ពន្ធលើការស្នាក់នៅ<br>- ការជួលការិយាល័យ<br>- ប្រភេទពន្ធផ្សេងៗទៀត | • **លោក ម៉ា បូរ៉ា**<br>អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម<br>• **អង្គសិក្ខាកាម** |
| | **វេទិកាចែករំលែក សំណួរ និងចម្លើយ** | • **លោក ម៉ា បូរ៉ា**<br>អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម<br>• **លោក សុខ ផៀង**<br>អនុប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ<br>• **អង្គសិក្ខាកាម** |
| 3:45-4:00 | **សម្រាកពិសារអាហារសម្រន់** | • **អង្គសិក្ខាកាម** |
| 4:00-4:40 | **<u>វគ្គទី៥:</u>**<br>• ផែនកាបន្ទាប់<br>• ការពិភាក្សាជ្រើសរើសប្រធានបទសម្រាប់វគ្គលើកក្រោយ<br>• ការវាយតម្លៃបញ្ចប់វគ្គ | • **អ្នកស្រី កែវ ម៉ារ៉ា**<br>អ្នកឯកទេសផ្នែកសិក្សារៀនសូត្រ អង្គការគសក<br>• **អង្គសិក្ខាកាម** |
| 4:40-4:50 | **សេចក្តីសនិដ្ឋានរួមនិងមតិបិទកម្មវិធី** | • **លោក យន ប៊ុនថុង**<br>ប្រធានផ្នែកប្រតិបត្តិការ<br>អង្គការគសក |

**<u>សំគាល់:</u>** **អង្គការគសកសូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីដោយផ្អែកលើលទ្ធភាពនៃវាគ្មិននិង បញ្ហាពេលវេលា ក្នុងករណីចាំបាច់។**